# សេចក្តីសង្ខេប

## សេចក្តីផ្តើម

ការវាយតម្លៃឯករាជ្យសម្រាប់ការសិក្សារៀនសូត្រលើកម្មវិធីកិច្ចការពារកុមាររបស់អង្គការយូនីសេហ្វ ត្រូវបានអនុវត្តដោយក្រុមវាយតម្លៃ Coram International ចាប់ផ្តើមនៅខែសីហាឆ្នាំ ២០១៧ ក្នុងបំណងដើម្បីបង្កើតភស្តុតាងអំពីអ្វីដែលដំណើរការបានល្អ អ្វីមិនដំណើរការមិនល្អ របៀបនៃដំណើរការ និងមូលហេតុ និងដើម្បីផ្តល់ភស្តុតាងជាមូលដ្ឋានព័ត៌មានសម្រាប់ការតាក់តែងកម្មវិធីប្រចាំប្រទេសថ្មី របស់អង្គការយូនីសេហ្វប្រចាំប្រទេសកម្ពុជា ឆ្នាំ ២០១៩-២០២៣។ ការវាយតម្លៃនេះ មានចេតនាដើម្បីជួយពង្រឹងការបំពេញការងារ និងគណនេយ្យភាពការងាររបស់អង្គការយូនីសេហ្វ ជាមួយរាជរដ្ឋាភិបាលកម្ពុជា ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អាជ្ញាធរខេត្ត អ្នកផ្តល់សេវាផ្នែកសង្គម ក្រុមប្រឹក្សាឃុំ ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ អង្គការសង្គមស៊ីវិល មេដឹកនាំសាសនា ប្រព័ន្ធផ្សព្វផ្សាយ និងអ្នកទទួលខុសត្រូវការងារផ្សេងទៀត។ ជាចុងក្រោយ ការវាយតម្លៃនេះ នឹងផ្តល់ព័ត៌មានជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍទ្រឹស្តីនៃការផ្លាស់ប្តូរថ្មី ដែលនឹងអនុញ្ញាតឱ្យអង្គការយូនីសេហ្វ អាចវាស់វែងវឌ្ឍនភាពនៅក្នុងការស្ថាបនាឱ្យមានការផ្លាស់ប្តូរជាប្រព័ន្ធទៅលើប្រព័ន្ធកិច្ចការពារកុមារនៅកម្ពុជា។

## កម្មវិធីកិច្ចការពារកុមាររបស់អង្គការយូនីសេហ្វនៅកម្ពុជា

នៅថ្ងៃទី ១០ ខែកុម្ភៈឆ្នាំ ២០១៦ រាជរដ្ឋាភិបាលកម្ពុជា និងអង្គការយូនីសេហ្វប្រចាំប្រទេសកម្ពុជាបានចុះហត្ថលេខាលើកម្មវិធីប្រចាំប្រទេសថ្មី ដែលគ្របដណ្តប់លើរយៈពេលចាប់ពី ខែមករា ឆ្នាំ ២០១៦ ដល់ខែធ្នូឆ្នាំ ២០១៨។ កម្មវិធីប្រចាំប្រទេសនេះ មានសមាសធាតុកម្មវិធីចំនួនបួន ហើយក្នុងនោះមានសមាសធាតុមួយដែលគ្រប ដណ្តប់លើអភិបាលកិច្ច និងកិច្ចការពារកុមារ។ លទ្ធផលរំពឹងទុកសម្រាប់កម្មវិធីកិច្ចការពារកុមារគឺ *"ត្រឹមឆ្នាំ ២០១៨ កុមារី និងកុមារងាយរងគ្រោះចំពោះអំពើហិង្សា និងជួបបទពិសោធន៍អំពើហិង្សា និងកុមារដែលត្រូវបានបំបែកពីគ្រួសារ ឬប្រឈមហានិភ័យនៃការបំបែកពីគ្រួសារ នឹងទទួលបានកិច្ចការពារកាន់តែច្រើនតាមរយៈក្របខ័ណ្ឌការងារផ្នែកស្ថាប័ន និងផ្នែកច្បាប់ សេវាមានគុណភាព និងបរិស្ថានសហគមន៍ប្រកបដោយការគាំទ្រ។"* ដើម្បីសម្រេចបានលទ្ធផលរំពឹងទុកនេះ កម្មវិធីកិច្ចការពារកុមារ (CP) បានប្រើប្រាស់អភិក្រមពង្រឹងប្រព័ន្ធនៅបីកម្រិតគឺៈ ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (លទ្ធផលរំពឹងទុកទី ១ របស់កម្មវិធី) អ្នកផ្តល់សេវា (លទ្ធផលរំពឹងទុកទី ២ របស់កម្មវិធី) ក៏ដូចជាកុមារ គ្រួសារ និងសហគមន៍ (លទ្ធផលរំពឹងទុកទី ៣ របស់កម្មវិធី)[1]។ ថវិកាសរុបសម្រាប់កម្មវិធីកិច្ចការពារកុមារគឺមានទឹកប្រាក់ ១១,៨ លានដុល្លារ សម្រាប់រយៈពេលចាប់ពីឆ្នាំ ២០១៦-២០១៨ ដោយក្នុងនោះ អន្តរាគមន៍ផ្តោតការយកចិត្តទុកដាក់នៅក្នុងរាជធានីខេត្តអាទិភាពចំនួនប្រាំគឺរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តព្រះសីហនុ ខេត្តសៀមរាប និងខេត្តបាត់ដំបង។

[1] កម្មវិធីនេះមានលទ្ធផលរំពឹងទុកទីបួនមួយទៀត ទាក់ទងនឹងសុខមាលភាពមនុស្សវ័យជំទង់ ប៉ុន្តែ ការវាយតម្លៃនេះពុំពិនិត្យលើលទ្ធផលរំពឹងទុកនេះទេ ព្រោះលទ្ធផលរំពឹងទុកនេះពុំពាក់ព័ន្ធដោយផ្ទាល់ជាមួយអភិក្រមកសាងប្រព័ន្ធ។

## វិធីសាស្ត្រ និងអតិក្រមនៃការវាយតម្លៃ

ការវាយតម្លៃនេះ ត្រូវបានតាក់តែងឡើង ដើម្បីពិចារណាលើប្រសិទ្ធភាព ភាពពាក់ព័ន្ធ ប្រសិទ្ធផល និងនិរន្តរភាពនៃកម្មវិធីរបស់អង្គការយូនីសេហ្វ[2] និងជាពិសេសថាតើ៖ *កម្មវិធីនេះបានចូលរួមចំណែកក្នុងការ បង្កើតលក្ខខណ្ឌជាវិជ្ជមាន និងការផ្លាស់ប្តូរដើម្បីរក្សាកុមារី និងកុមារាងាយរងគ្រោះឱ្យនៅជាមួយក្រុមគ្រួសារ គាំទ្រដល់ការធ្វើសមាហរណកម្មកុមារទាំងនោះដោយសុវត្ថិភាពត្រលប់ទៅទទួលការថែទាំពីគ្រួសារនិងការពារពួកគេពីអំពើហិង្សាបានកម្រិតណា ភាពពាក់ព័ន្ធ និងសង្គតភាពរបស់កម្មវិធីនេះជាមួយអាទិភាពជាតិ និងការប្តេជ្ញាចិត្តរបស់អង្គការយូនីសេហ្វ របៀបដែលអង្គការយូនីសេហ្វគៀងគរធនធានដើម្បីកែលម្អការសម្របសម្រួល និងសម្រេចបានលទ្ធផល ព្រមទាំងទំហំនៃការផ្លាស់ប្តូរដែលកម្មវិធីសម្រេចបានដែលនឹងបន្តក្រោយពេលកម្មវិធីនេះបានបញ្ចប់។*

អ្នកវាយតម្លៃបានប្រើប្រាស់វិធីសាស្ត្រផ្អែកលើទ្រឹស្តី ដែលព្យាយាមកំណត់ថាតើកម្មវិធីកិច្ចការពារកុមាររបស់អង្គការយូនីសេហ្វបានដើរនៅលើគន្លងត្រឹមត្រូវ (ឬទេ) ក្នុងការឈានទៅសម្រេចបាននូវចក្ខុវិស័យដើម្បីការផ្លាស់ប្តូររបស់ខ្លួន បានដោយរបៀបណា និងហេតុអ្វី។ វិធីសាស្ត្រចម្រុះមួយត្រូវបានកែសម្រួលយកមកប្រើប្រាស់ ដើម្បីប្រមូលទិន្នន័យដែលមានលក្ខណៈសម្បូរបែប ត្រឹមត្រូវ និងអាចវាស់វែងបាន និងដើម្បីអនុញ្ញាតឱ្យអាចប្រៀបធៀបទិន្នន័យបាន។

- ប្រភពទិន្នន័យបែបគុណភាព រួមមានការពិនិត្យឯកសារ ការសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះ ការសម្ភាសន៍ករណីសិក្សាស៊ីជម្រៅជាមួយកុមារ និងអ្នកថែទាំកុមារដែលបានទទួលការគាំទ្រនៅក្រោមកម្មវិធី និងការពិភាក្សាក្រុមគោលដៅជាមួយសមាជិកសហគមន៍ និងឪពុកម្តាយ។ ប្រភពទិន្នន័យបែបបរិមាណ រួមមានការវិភាគលើការគ្រប់គ្រងករណី និងទិន្នន័យការពិនិត្យតាមដាន ការពិនិត្យសំណុំឯកសារករណី និងការចែកទម្រង់ស្ទង់មតិមានរចនាសម្ព័ន្ធដល់អ្នកទទួលផល មានដូចជាអ្នកថែទាំកុមារ និងកុមារដែលកំពុងឆ្លងកាត់ដំណើរការធ្វើសមាហរណកម្ម។

ថ្វីបើការប្រមូលទិន្នន័យបានផ្តោតការយកចិត្តទុកដាក់លើរាជធានីខេត្តគោលដៅទាំងប្រាំ របស់កម្មវិធីកិច្ចការពារកុមារក្តី ប៉ុន្តែខេត្តសម្រាប់ធ្វើការប្រៀបធៀប (ខេត្តមិនបានទទួលអន្តរាគមន៍) ចំនួនបួនខេត្តទៀត ត្រូវបានរួមបញ្ចូលផងដែរ ដើម្បីបង្ហាញឱ្យឃើញថាតើកិច្ចគាំទ្រពីអង្គការយូនីសេហ្វបានរួមចំណែកយ៉ាងណាខ្លះចំពោះទិដ្ឋភាពនានានៃការបង្ការ និងការឆ្លើយតបក្នុងកិច្ចការពារកុមារ៖

- ការសម្ភាសន៍បែបគុណភាពសរុបចំនួន ១៧៨ ត្រូវបានធ្វើឡើងក្នុងអំឡុងពេលការវាយតម្លៃនេះ ដោយក្នុងនោះរួមមានទាំង Key Informant Interviews (KIIs) ចំនួន ៣៨ នៅថ្នាក់ជាតិ KIIs ចំនួន ៩០ នៅទីតាំងអន្តរាគមន៍ និង KIIs ចំនួន ២៩ នៅទីតាំងប្រៀបធៀប ការសម្ភាសន៍ស៊ីជម្រៅជាមួយកុមារចំនួន ១២ (កុមារី ៨ នាក់ និងកុមារាចំនួន ៤ នាក់) និង ការសម្ភាសន៍ស៊ីជម្រៅជាមួយឪពុកម្តាយចំនួន ១០ (ស្ត្រី ៩ នាក់ និង

[2] វិធីសាស្ត្រនេះត្រូវបានរៀបចំអនុលោមតាមក្របខ័ណ្ឌលក្ខខ័ណ្ឌវិនិច្ឆ័យការវាយតម្លៃរបស់ អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍ/គណៈកម្មាធិការជំនួយអភិវឌ្ឍ (OECD/DAC) និងត្រូវបានអភិវឌ្ឍឡើងអនុលោមតាមនិយាម និងបទដ្ឋានការវាយតម្លៃរបស់ UNEG (2016)។

បុរស ១ នាក់)។ ការសម្ភាសន៍ក្រុមគោលដៅចំនួន ១៨ ក្រុមត្រូវបានធ្វើឡើងជាមួយសមាជិកសហគមន៍ (ស្ត្រី ៦៨ នាក់ និងបុរស ២០ នាក់)។ កុមារចំនួន ១៤៣ នាក់ដែលកំពុងឆ្លងកាត់ដំណើរការសមាហរណកម្ម ត្រូវបានទាក់ទងដើម្បីធ្វើការសម្ភាសន៍ ដោយក្នុងនោះមានកុមារា ៦៦ នាក់ និងកុមារី ៧៧។ អ្នកថែទាំកុមារចំនួន ៧៣ នាក់ ក៏បានចូលរួមក្នុងការស្ទង់មតិផងដែរដោយក្នុងនោះមានស្ត្រី ៦៧ នាក់ និងបុរស ៦ នាក់។ ការពិនិត្យសំណុំឯកសារសរុបចំនួន ១០ សំណុំឯកសារត្រូវបានធ្វើឡើងក្នុងអំឡុងពេលការវាយតម្លៃនេះ។

ពិធីសារផ្នែកក្រមសីលធម៌សម្រាប់ការវាយតម្លៃនេះ ត្រូវបានបង្កើតឡើងដើម្បីជាមគ្គុទ្ទេសក៍សម្រាប់ការវាយតម្លៃ អនុលោមទៅតាមគោលការណ៍ណែនាំផ្នែកក្រមសីលធម៌របស់ក្រុមវាយតម្លៃអង្គការសហប្រជាជាតិ នីតិវិធីរបស់អង្គការយូនីសេហ្វសម្រាប់បទដ្ឋានក្រមសីលធម៌ក្នុងការស្រាវជ្រាវ ការវាយតម្លៃ ការប្រមូល និងវិភាគទិន្នន័យ និងគោលការណ៍ណែនាំផ្នែកក្រមសីលធម៌របស់អង្គការ Coram International ផ្ទាល់។

## គំហើញ៖ ប្រសិទ្ធភាពនៃការឆ្លើយតបរបស់កម្មវិធីកិច្ចការពារកុមារ

ចាប់តាំងពីឆ្នាំ ២០១៦ មក កម្មវិធីកិច្ចការពារកុមាររបស់អង្គការយូនីសេហ្វបានគៀងគររាជរដ្ឋាភិបាលនិងភាគីពាក់ព័ន្ធនានារបស់រដ្ឋាភិបាល ដើម្បីធ្វើការប្តេជ្ញាចិត្តដែលអាចធ្វើសកម្មភាពបានឆ្ពោះទៅអភិវឌ្ឍឱ្យមានប្រព័ន្ធកិច្ចការពារកុមារថ្នាក់ជាតិ និងការផ្តល់ការឆ្លើយតបក្នុងការការពារកុមារ (សេវា)។ កិច្ចខិតខំទាំងនេះ បានរួមចំណែកធ្វើឱ្យសម្រេចបាននូវសមិទ្ធិផលផ្នែកគោលនយោបាយមួយចំនួនដូចជា "ផែនការសកម្មភាពស្តីពីអំពើហិង្សាលើកុមារ" (ឆ្នាំ ២០១៧) និងផែនការសកម្មភាពលើកកម្ពស់ការថែទាំកុមារ (ឆ្នាំ ២០១៧) ដែលបានត្រួសត្រាយផ្លូវសម្រាប់ការផ្លាស់ប្តូរប្រកបដោយអត្ថន័យ។ អង្គការយូនីសេហ្វក៏បានផ្តល់ធាតុចូលសំខាន់ៗទៅក្នុងផែនការរបស់រដ្ឋាភិបាលដើម្បីដាក់ឱ្យមានប្រតិបត្តិការនូវសេវាកិច្ចការពារកុមារ និងជាពិសេសគឺអង្គភាពបច្ចេកទេសកិច្ចការពារកុមារ នៅក្នុងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ប៉ុន្តែ គំហើញពីការវាយតម្លៃនេះបង្ហាញឱ្យឃើញថា ថ្វីបើអង្គការយូនីសេហ្វបានរួមចំណែកក្នុងការបង្កើតឱ្យមានក្របខ័ណ្ឌផ្នែកស្ថាប័នសម្រាប់ការឆ្លើយតបចំពោះកិច្ចការពារកុមារក្តី ប៉ុន្តែ ក្របខ័ណ្ឌផ្នែកស្ថាប័ននេះនៅមិនទាន់ត្រូវបានប្រែក្លាយទៅជាប្រព័ន្ធកិច្ចការពារកុមារដោយមានការសម្របសម្រួល ដែលមានសមត្ថភាពក្នុងការកំណត់អត្តសញ្ញាណ និងការឆ្លើយតបចំពោះករណីកិច្ចការពារកុមារនៅឡើយទេ។ ផ្ទុយទៅវិញ ប្រព័ន្ធកិច្ចការពារកុមារថ្នាក់ជាតិ (រួមទាំងបុគ្គលិកសង្គមកិច្ចរបស់រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល) ផ្តោតការយកចិត្តទុកដាក់ភាគច្រើនតែទៅលើការធ្វើសមាហរណកម្មកុមារពីមណ្ឌលថែទាំកុមារ និងការផ្តល់ "សេវាបង្ការ" កម្រិតមូលដ្ឋានប៉ុណ្ណោះ។

គំហើញពីការវាយតម្លៃបានឱ្យដឹងថា នៅពេលករណីមួយត្រូវបានកំណត់ និងទទួលបានការឆ្លើយតបផ្នែកកិច្ចការពារកុមារ "ជាផ្លូវការ" សេវានេះច្រើនតែផ្តល់ដោយអ្នកផ្តល់សេវាជាអង្គការមិនមែនរដ្ឋាភិបាល។ ប្រភេទសេវាដែលត្រូវបានផ្តល់ឱ្យគឺមានលក្ខណៈខុសៗគ្នា និងថ្វីបើការងារកិច្ចការពារកុមារជាវិជ្ជមានមួយចំនួនត្រូវបានធ្វើឡើងហើយក្តី ប៉ុន្តែ ការវាយតម្លៃនេះបានរកឃើញថានៅចាំបាច់ត្រូវការឱ្យមានការវាយតម្លៃដែលមានលក្ខណៈវិជ្ជាជីវៈបន្ថែមទៀតទៅលើស្ថានភាពរបស់កុមារ ទំនាក់ទំនងគ្រួសារ និងហានិភ័យ ដែលកត្តាទាំងនោះអាចបង្កឡើងចំពោះកុមារ។ ករណី

មួយចំនួនបានទទួលការឆ្លើយតបមានលក្ខណៈជាបុគ្គល ដែលត្រូវបានរៀបចំឡើងដើម្បីកាត់បន្ថយហានិភ័យ ដែលភាគច្រើនគឺបង្កឡើងដោយសារកង្វះការផ្តល់សេវា។ ការវាយតម្លៃបានរកឃើញថា អាជ្ញាធររដ្ឋាភិបាលមិនបានចូលរួមនៅក្នុងការគ្រប់គ្រងករណីដែលមានលក្ខណៈប្រកបដោយបទដ្ឋានក្នុងករណីកិច្ចការពារកុមារឡើយ។

ជាមួយនឹងយន្តការឆ្លើយតបមានលក្ខណៈទន់ខ្សោយនេះ ការកំណត់អត្តសញ្ញាណ និងការបញ្ជូនករណីកិច្ចការពារកុមារ ជារឿយៗតែងមានភាពមិនគ្រប់គ្រាន់ ដោយក្នុងនោះរួមមានទាំងករណីដែលគេបានដឹងថាកុមារបានជួបប្រទះអំពើហិង្សា។ អ្នកផ្តល់ចម្លើយ បានលើកឧទាហរណ៍ជាច្រើន អំពីករណីដែលត្រូវបានបញ្ជូនទៅឱ្យអាជ្ញាធរសមស្រប តែនៅក្រោយពេលកុមារបានជួបគ្រោះថ្នាក់គួរជាទីកត់សម្គាល់ ឬករណីដែលអាជ្ញាធរបានដឹងអំពីករណីនោះហើយ ប៉ុន្តែមិនបានឆ្លើយតបចំពោះករណីនោះឱ្យបានត្រឹមត្រូវ។ ការយឺតយ៉ាវក្នុងការកំណត់អត្តសញ្ញាណ និងការបញ្ជូន ត្រូវបានធ្វើឱ្យកាន់តែធ្ងន់ធ្ងរថែមទៀតដោយកង្វះភាពច្បាស់លាស់ជុំវិញច្រកផ្លូវដើម្បីធ្វើការបញ្ជូន ក៏ដូចជាអំពីតួនាទី និងការទទួលខុសត្រូវរបស់អាជ្ញាធរពាក់ព័ន្ធ និងការយល់ដឹងទន់ខ្សោយរបស់អ្នកផ្តល់សេវាអំពីរបៀបវាយតម្លៃ និងចាត់ចំណាត់ថ្នាក់ហានិភ័យ។

## គំហើញ៖ ប្រសិទ្ធភាពនៃកម្មវិធីសមាហរណកម្ម

ចាប់តាំងពីឆ្នាំ២០១៦ កម្មវិធីរបស់អង្គការយូនីសេហ្វ បានផ្តោតជាពិសេសលើសូចនាករលទ្ធផលទី១៖ ការបង្រួបបង្រួមកុមារចំនួន ៣០% ដែលកំពុងរស់នៅក្នុងមណ្ឌលថែទាំកុមារ ជាមួយគ្រួសាររបស់ពួកគេ ឬ ទុកដាក់ក្រោមការថែទាំលក្ខណៈគ្រួសារ ត្រឹមដំណាច់ឆ្នាំ២០១៨។

> "ការបង្រួបបង្រួម" សំដៅចំពោះការបញ្ជូនកុមារទៅកាន់គ្រួសារដែលកុមាររស់នៅពីមុន មុនពេលចូលមករស់នៅក្នុងមណ្ឌលថែទាំកុមារ ដោយឡែក "សមាហរណកម្ម" សំដៅចំពោះ *ដំណើរការ*របស់កុមារ ដែលកំពុងធ្វើនូវអ្វីដែលសង្ឃឹមថាជាការផ្លាស់ប្តូរចិន្ត្រេយ៍ ទៅជាការទុកដាក់តាមគ្រួសារ ឬ តាមសហគមន៍។

ការគៀងគរភាពជាដៃគូរបស់អង្គការយូនីសេហ្វ ដើម្បីលើកកម្ពស់សមាហរណកម្មកុមារចេញពីមណ្ឌលថែទាំកុមារ ត្រូវបានរកឃើញថាមានប្រសិទ្ធភាពខ្ពស់។ ជាពិសេស អង្គការយូនីសេហ្វ សម្រេចបានការទទួលយក និង ការប្តេជ្ញាចិត្តគួរឱ្យកត់សម្គាល់ ពីរាជរដ្ឋាភិបាលកម្ពុជា ក្នុងការបោះជំហានឆ្ពោះទៅរកគោលដៅលើកកម្ពស់ការថែទាំតាមគ្រួសារសម្រាប់កុមាររាប់ពាន់នាក់ ដែលកំពុងរស់នៅក្នុងមណ្ឌលថែទាំកុមារក្នុងប្រទេសកម្ពុជា ដូចមានភស្តុតាងបញ្ជាក់តាមរយៈការសម្រេចបាននូវគោលនយោបាយសំខាន់ៗមួយចំនួន នៅកម្រិតថ្នាក់ជាតិ រួមមានការដែលរាជរដ្ឋាភិបាលបានដាក់ចេញនូវអនុក្រឹត្យលេខ ១១៩ ស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ ក្នុងខែកញ្ញា ឆ្នាំ២០១៥ និង ការអភិវឌ្ឍផែនការសកម្មភាពសម្រាប់កែលម្អការងារថែទាំកុមារ ដែលចុះហត្ថលេខាដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅចុងឆ្នាំ២០១៦ និង គោលនយោបាយសំខាន់ៗដទៃទៀត។

យោងតាមទិន្នន័យដែលមន្ទីរ ស.អ.យ បានផ្តល់ជូនក្នុងពេលវាយតម្លៃ បានឱ្យដឹងថាមានកុមារ និងយុវជនសរុបចំនួន ១.០៦៥នាក់ បានចាប់ផ្តើមដំណើរការសមាហរណកម្មពីមណ្ឌលថែទាំកុមារ នៅក្នុងរាជធានីខេត្តគោលដៅទាំង៥ ចន្លោះពីខែមករា ឆ្នាំ២០១៦ រហូតដល់ ខែមេសា ឆ្នាំ២០១៨។ តួលេខកុមារ និងយុវជនចំនួន ១.០៦៥នាក់នេះ

រួមមានកុមារចំនួន ៥៨២នាក់ ដែលការទុកដាក់ធ្វើសមាហរណកម្មលើកដំបូងរបស់ពួកគេ បានធ្វើឡើងនៅពេលដែលពួកគេមានអាយុក្រោម ១៨ឆ្នាំ[3] និង មានយុវជនចំនួន ៤៨៣នាក់ ដែលមានអាយុលើស ១៨ឆ្នាំ។ កុមារ និងយុវជនចំនួន ៧៤០នាក់ ត្រូវបានកត់ត្រាថាបានទទួលការទុកដាក់តាមគ្រួសារ ឬ តាមសហគមន៍ ត្រឹមខែមេសា ឆ្នាំ២០១៨ និងមានកុមារចំនួន២៥នាក់ ដែលត្រូវបានផ្ទេរទៅមណ្ឌលថែទាំកុមារថ្មី និង កុមារចំនួន ៣០០នាក់ទៀត កំពុងរង់ចាំការទុកដាក់។ ក្នុងចំណោមកុមារចំនួន ៥៨២នាក់ ដែលមានអាយុក្រោម ១៨ឆ្នាំ មានកុមារចំនួន ៣៨៩នាក់ (៦៤,៤%) ត្រូវបានកត់ត្រាថាកំពុងត្រូវបានបង្រួបបង្រួមជាមួយឪពុកម្តាយបង្កើត និង ២០,៩% ត្រូវបានទុកដាក់ក្រោមការថែទាំដោយគ្រួសារសាច់ញាតិ និង ៦,៨% ត្រូវបានទុកដាក់នៅក្នុងផ្ទះស្នាក់នៅជាក្រុម។ គំហើញ (ដែលបានរកឃើញថាកុមារភាគច្រើនដែលត្រូវបានទុកដាក់មកទល់នឹងបច្ចុប្បន្ន ត្រូវបានបង្រួបបង្រួមជាមួយឪពុកម្តាយបង្កើតរបស់ពួកគេ) ឆ្លុះបញ្ចាំងអំពីគោលការណ៍ទី១ នៅក្នុងផែនការសកម្មភាពដើម្បីកែលម្អការថែទាំកុមារ (២០១៦-២០១៨) ដែលចែងថា "ចាំបាច់ត្រូវពិនិត្យលទ្ធភាពក្នុងការធ្វើសមាហរណកម្មជាមួយគ្រួសារបង្កើតរបស់កុមារ ជាអាទិភាពទី១"។

ជាទូទៅ គំហើញពីការវាយតម្លៃបានបង្ហាញឱ្យឃើញអំពីអត្ថប្រយោជន៍ក្នុងការទទួលបានកិច្ចការពាររបស់កម្មវិធីសមាហរណកម្ម សម្រាប់លើកកម្ពស់សុវត្ថិភាព និងសុខុមាលភាពរបស់កុមារ។ អ្នកចូលរួមបានលើកឡើងអំពីអត្ថប្រយោជន៍របស់កម្មវិធី ដូចជា ការថែទាំដែលមានគុណភាពខ្ពស់ជាង និង មានការយកចិត្តទុកដាក់ខ្លាំងជាងការភ្ជាប់ទំនាក់ទំនងជាមួយសហគមន៍ ឱកាសចូលរួមនៅក្នុងជីវិតសង្គម និងវប្បធម៌ ព្រមទាំងលទ្ធភាពក្នុងការអភិវឌ្ឍបំណិនជីវិតសំខាន់ៗ។[4]

ការស្ទង់មតិមួយទៅលើកុមារដែលត្រូវបានធ្វើសមាហរណកម្ម ចំនួន១៤៣នាក់ ដែលត្រូវបានទុកដាក់នៅក្នុងសហគមន៍ ឬ បង្រួបបង្រួមជាមួយគ្រួសាររបស់ពួកគេ បានរកឃើញថា កុមារចំនួន ៥៥,២% មានអារម្មណ៍ថាមានសុវត្ថិភាពជាងមុននៅក្នុងគ្រួសាររបស់ពួកគេ ឬ ការទុកដាក់នៅក្នុងសហគមន៍ បើធៀបទៅនឹងការរស់នៅក្នុងមណ្ឌល និង ២១% ទៀតបានប្រាប់ឱ្យដឹងថា ពួកគេពុំមានអារម្មណ៍ថាខុសគ្នាអ្វីឡើយ ទាក់ទងនឹងសុវត្ថិភាពរបស់ពួកគេ បើធៀបទៅនឹងពេលដែលពួកគេរស់នៅក្នុងមណ្ឌលថែទាំកុមារ។ ប៉ុន្តែ បើទោះជាដូច្នេះក្តី មានកុមារស្ទើរតែ១នាក់ ក្នុងចំណោម៤នាក់ (២៣,៨%) បានប្រាប់ឱ្យដឹងថា ពួកគេមានអារម្មណ៍ថាការរស់នៅក្នុងមណ្ឌលមានសុវត្ថិភាពជាង។ គំហើញទាំងនេះមានការគាំទ្រពីភស្តុតាងដែលទទួលបានពីការស្រាវជ្រាវបែបគុណភាព។ បន្ថែមពីនេះទៀត បើទោះបីជាបុគ្គលិកសង្គមកិច្ច និង អ្នកអនុវត្តការងារដទៃទៀតដែលកំពុងធ្វើការងារដោយផ្ទាល់លើការងារសមាហរណកម្មហាក់មានទំនោរសង្កត់ធ្ងន់ថា (នៅក្នុងការយល់ឃើញរបស់ពួកគេ) ករណីសមាហរណកម្មភាគច្រើនទទួលបានជោគជ័យក៏ដោយ ប៉ុន្តែ ពួកគេមិនអាចចង្អុលបង្ហាញអំពីឧទាហរណ៍ជាច្រើនទាក់ទងនឹងករណីដែលអ្វីៗមិនបានដំណើរការទៅតាមផែនការ និង ការដែលការទុកដាក់ធ្វើសមាហរណកម្មទទួលរងបរាជ័យឡើយ។

---

[3] កុមារចំនួន ៥៨២នាក់ ស្មើនឹងប្រមាណ ៥% នៃកុមារចំនួន ១១.៧៨៨នាក់ ដែលត្រូវបានរាប់ថាកំពុងរស់នៅក្នុងមណ្ឌលថែទាំកុមារ ក្នុងរាជធានីខេត្តគោលដៅទាំង៥ ត្រឹមដើមឆ្នាំ២០១៦។[3]

[4] កិច្ចសម្ភាសន៍ប្រធានមណ្ឌលថែទាំកុមារ ខេត្តកំពង់ធំ ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៧។

បើទោះបីជាការធ្វើសមាហរណកម្ម ទទួលបានមគ្គុទ្ទេសក៍ណែនាំពីគោលការណ៍សំខាន់ៗនៅក្នុងផែនការសកម្មភាព (ថា "ឧត្តមប្រយោជន៍" របស់កុមារត្រូវតែជាមូលដ្ឋានកំណត់ទៅលើការសម្រេចចិត្តនានាទាក់ទងនឹងការធ្វើសមាហរណកម្ម និង រាល់ដំណើរការសមាហរណកម្មទាំងអស់ គប្បីមានគោលបំណងផ្តល់ប្រយោជន៍ និង មិនបង្កគ្រោះថ្នាក់ដល់កុមារ) ក៏ដោយ ប៉ុន្តែក៏នៅមានចំណុចខ្សោយជាច្រើនក្នុងការអនុវត្តកម្មវិធីសមាហរណកម្ម ត្រូវបានកំណត់រកឃើញ។ ការត្រួតពិនិត្យឯកសារករណី បានបង្ហាញឱ្យដឹងថា ការប៉ាន់ប្រមាណក្នុងការធ្វើសមាហរណកម្មនៅមានលក្ខណៈមូលដ្ឋាននៅឡើយ ជាមួយនឹងទម្រង់ដែលមិនតម្រូវឱ្យបុគ្គលិកសង្គមកិច្ចធ្វើការសាកសួរលម្អិតខ្លាំង និងការសម្រេចចិត្តធ្វើសមាហរណកម្មកុមារ រមែងតែងមានការរុញច្រានពីការដែលកុមារមានឪពុកម្តាយដែលនៅរស់ និងឆន្ទៈរបស់ឪពុកម្តាយ ឬ ការដែលមានសមាជិកគ្រួសារដទៃទៀតក្នុងការទទួលយកកុមារ (ឬការបិទមណ្ឌលថែទាំកុមារ) ជាជាងការវិភាគហានិភ័យឱ្យបានគ្រប់ជ្រុងជ្រោយ និង ការប៉ាន់ប្រមាណឧត្តមប្រយោជន៍របស់កុមារ។ បន្ថែមពីនេះទៀត សេវាតាមដាន និងគាំទ្រគ្រួសារ និងកុមារ ដើម្បីសម្របសម្រួលដល់ការធ្វើសមាហរណកម្ម ត្រូវបានរកឃើញថានៅមានកម្រិត។ ស្របពេលជាមួយគ្នានេះដែរ គ្រួសារជាច្រើនដែលត្រូវបានសម្ភាសន៍ ត្រូវបានរកឃើញថាកំពុងជួបប្រទះបញ្ហាស្មុគស្មាញជាច្រើន ក្នុងនោះរួមមានការជំពាក់បំណុល គ្រឿងស្រវឹង ការប្រើប្រាស់បំពាន គ្រឿងញៀន អំពើហិង្សាក្នុងគ្រួសារ ជំងឺរ៉ាំរ៉ៃ ពិការភាព និង អសន្តិសុខផ្នែកលំនៅដ្ឋាន។ បុគ្គលិកសង្គមកិច្ចមួយចំនួន បានបង្ហាញឱ្យឃើញអំពីកង្វល់ទាក់ទងនឹងសមត្ថភាពរបស់ពួកគេ ក្នុងការគ្រប់គ្រងបញ្ហាប្រឈមមួយចំនួនបន្ថែមទៀត និង បានសង្កត់ធ្ងន់អំពីសេចក្តីត្រូវការរបស់ពួកគេដើម្បីឱ្យមានការបណ្តុះបណ្តាលបន្ថែមទៀតក្នុងជំនាញការងារសង្គមកិច្ច។

កុមារនៃគ្រួសារដែលកាន់តែក្រីក្រ ត្រូវបានរកឃើញថាមិនសូវមានដំណើរការល្អឡើយ នៅក្នុងការទុកដាក់ធ្វើសមាហរណកម្មរបស់ពួកគេ៖ ពួកគេមិនសូវទំនងថាមានអារម្មណ៍ទទួលបានការស្រឡាញ់ពីអ្នកថែទាំរបស់ពួកគេ មិនសូវមានអារម្មណ៍ថាគេចង់បានពួកគេ មិនសូវមានអារម្មណ៍ថាមានគេស្តាប់សម្តីពួកគេ និង ទំនងនឹងមានអារម្មណ៍ឯកោ និងដាច់ដោយឡែកពីគេឯង។ បន្ថែមពីនេះទៀត កុមារីត្រូវបានរកឃើញថាមានដំណើរការមិនសូវល្អដូចកុមារាឡើយ។ កុមារីក្នុងចំនួនសមាមាត្រតិចជាងកុមារាបន្តិច បានឆ្លងកាត់ដំណើរការសមាហរណកម្ម និង កុមារពិការព្រមទាំងកុមារតូច ក៏ត្រូវបានរកឃើញផងដែរថា មិនមានភាពជាតំណាងគ្រប់គ្រាន់នៅក្នុងទិន្នន័យអំពីករណី។គំហើញទាំងនេះបានឱ្យដឹងថា កម្មវិធីសមាហរណកម្មមិនទាន់គាំទ្រដល់កុមារដែលត្រូវការបំផុតនូវការថែទាំតាមគ្រួសារ និងតាមសហគមន៍នៅឡើយទេ។ ជារួម គំហើញពីការវាយតម្លៃបានបង្ហាញឱ្យឃើញអំពីសេចក្តីត្រូវការឱ្យមាននូវកិច្ចគាំទ្រផ្នែកការងារសង្គមកិច្ចទៅតាមសេចក្តីត្រូវការ មានលក្ខណៈឯកទេស និង មានភាពរឹងមាំ សម្រាប់ផ្តល់ជូនដល់កុមារ និងគ្រួសារងាយរងគ្រោះបំផុត ដោយរាប់បញ្ចូលទាំងកុមារតូច កុមារី កុមារពិការ និងកុមារដែលរស់នៅក្នុងគ្រួសារក្រីក្រ។ គេក៏ត្រូវការរៀបចំផែនការថែទាំជំនួសផងដែរ ក្នុងករណីការទុកដាក់កុមារមានការបែកបាក់ ឬ បរាជ័យ ឬ ក្នុងករណីដែលកុមារបន្តស្ថិតនៅក្នុងការទុកដាក់នោះ មិនបម្រើឱ្យឧត្តមប្រយោជន៍របស់កុមារ។

## ប្រសិទ្ធភាពនៃកម្មវិធីបង្ការ

សមាសធាតុដ៏ធំមួយនៃកម្មវិធីបង្ការរបស់អង្គការយូនីសេហ្វ គឺការផ្តល់សេវាតាមរយៈភាពជាដៃគូ 3PC ដល់បុគ្គលជាកុមារ និងគ្រួសារដែលត្រូវបានកំណត់អត្តសញ្ញាណថា "មានការប្រឈម" នៅតាមបណ្តាខេត្តគោលដៅ ដូចជាកុមារក្រីក្រ កុមារអនាថា កុមារនៅក្រៅសាលារៀន ឬគ្រួសារប្រឈមទៅនឹងការបំបែកកុមារពីគ្រួសារ។ យោងតាមរបាយការណ៍ពិនិត្យតាមដានរបស់អង្គការយូនីសេហ្វបានឱ្យដឹងថា កុមារចំនួន ៩.១៨៥ នាក់បានទទួលផលពីសេវាកម្មគោលដៅនៅឆ្នាំ ២០១៦ ហើយនៅឆ្នាំ ២០១៧ មានកុមារ ៨.៤១៥ នាក់បានទទួលផល។ ទិន្នន័យដែលមានបង្ហាញឱ្យដឹងថា សេវាដែលត្រូវបានផ្តល់ឱ្យច្រើនបំផុត មានដូចជាសេវាគាំទ្រដល់ការអប់រំ (៨.៨១៣ នាក់នៅឆ្នាំ ២០១៧) បន្ទាប់មកទៀតគឺការចូលរួមនៅក្នុងព្រឹត្តិការណ៍ចុះផ្សព្វផ្សាយ តាមមូលដ្ឋាន (៧.៥២២ នាក់នៅឆ្នាំ ២០១៧) និងការប្រឹក្សាយោបល់ (៧.១៩៣ នាក់នៅឆ្នាំ ២០១៧)។ គំហើញតាមរយៈទិន្នន័យបែបគុណភាពក្នុងការវាយតម្លៃនេះ អះអាងបញ្ជាក់ថា ភាគច្រើនលើសលប់នៃការ គាំទ្រដែលដៃគូ 3PC បានផ្តល់ដល់កុមារ គឺមានដូចជាការគាំទ្រផ្នែកសម្ភារៈចាំបាច់ជាមូលដ្ឋានទាក់ទងជាមួយការអប់រំ ដូចជាការផ្តល់សម្ភារៈសិក្សា ការផ្តល់កង់ ឬសេវារថយន្តដឹកជញ្ជូនដើម្បីឱ្យកុមារបានទៅសាលារៀន ហើយក្នុងករណីមួយចំនួនទៀតក៏មានការរៀបចំផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈកម្រិតមូលដ្ឋានផងដែរ។ ការគាំទ្រផ្នែកសេចក្តីត្រូវការជាមូលដ្ឋាន និងការគាំទ្រក្នុងការចិញ្ចឹមបីបាច់កូន កម្រត្រូវបានផ្តល់ឱ្យណាស់។ គួរកត់សម្គាល់ថា មានសេវាតិចតួចប៉ុណ្ណោះដែលបានផ្តល់ដល់កុមារ ផ្ទុកមេរោគអេដស៍ និងកុមារពិការ៖ ក្រុមទាំងពីរនេះមានសមាមាត្រប្រមាណ 0,1% នៃកុមារងាយរងគ្រោះនៅក្នុងគ្រួសារដែលត្រូវបាន គាំទ្រដោយ 3PC នៅឆ្នាំ ២០១៧ ដែលជាការបញ្ជាក់ឱ្យឃើញថា ចាំបាច់ត្រូវមានកិច្ចខិតខំឱ្យច្រើនជាងនេះបន្ថែមទៀត ដើម្បីផ្តោតជាពិសេសក្នុងការកំណត់អត្តសញ្ញាណកុមារបាត់បង់ឱកាស។[5]

ទិន្នន័យពិនិត្យតាមដាន 3PC បានឱ្យឃើញថា ការគាំទ្រមួយចំនួនក្នុងផ្នែកការបង្ការ មានប្រសិទ្ធភាពក្នុងការដោះស្រាយកត្តាហានិភ័យជាបុព្វហេតុឫសគល់៖ ៧៨% នៃអាជីវកម្មលក្ខណៈគ្រួសារ ដែលបានទទួលការគាំទ្រផ្នែកជីវភាពរស់នៅក្នុងឆ្នាំ ២០១៦ នៅបន្តបើកដំណើរការក្រោយរយៈពេលប្រតិបត្តិការបានមួយឆ្នាំ ហើយអ្នកចូលរួមក្នុងក្រុមគាំទ្រផ្នែកគ្រឿងស្រវឹង បានរាយការណ៍ទាំងអំពីការថយចុះទទួលទានផឹកគ្រឿងស្រវឹង (៥៨%) និងការថយចុះអំពើហិង្សានៅក្នុងគ្រួសាររបស់ពួកគេ (៧៨%) នៅក្នុងការស្ទង់មតិបញ្ចប់ឆ្នាំ (២០១៧)។[6] ទិន្នន័យបែបគុណភាពដែលបានពីការវាយតម្លៃស្តីពីលទ្ធផលរំពឹងទុក និង ឥទ្ធិពលនៃការគាំទ្រផ្នែកកិច្ចការពារមានលក្ខណៈចម្រុះគ្នាជាច្រើន។ អ្នកទទួលផលជាច្រើន បង្ហាញការអរគុណជាមូលដ្ឋានចំពោះការគាំទ្រដែលបានផ្តល់ឱ្យ ហើយក្នុងករណីជាច្រើន យើងឃើញថាការគាំទ្របានធ្វើឱ្យមានភាពខុសប្លែកប្រកបដោយអត្ថន័យនៅក្នុងជីវិតអ្នកទទួលផល និងបានកាត់បន្ថយលទ្ធភាពនៃការកើតអំពើហិង្សា និងការបំបែកកុមារពីគ្រួសារ។ ប៉ុន្តែ យើងបានរកឃើញថា ក្នុងករណីមួយចំនួន សេវាគាំទ្រផ្នែកបង្ការមានផលប៉ះពាល់តិចតួចប៉ុណ្ណោះលើស្ថានភាពរបស់អ្នកទទួលផល។ ជារឿយៗ ប្រភេទនៃការគាំទ្រដែលត្រូវបានផ្តល់ឱ្យត្រូវបានបង្កើតរួចជាស្រេចតាំងពីមុន ហើយតាមធម្មតាមិនត្រូវបានកែតម្រូវសម្របទៅតាម

---

[5] របាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសរបស់អង្គការយូនីសេហ្វ ដាក់ជូនទៅទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ, USAID, 2017

[6] ក្របខ័ណ្ឌត្រួតពិនិត្យរបស់ 3PC, 2017

សេចក្តីត្រូវការជាក់លាក់របស់អ្នកទទួលផលទេ។ លើសពីនេះ និងសំខាន់ជាងនេះទៀតនោះគឺ មិនមានការផ្តល់ជូននូវទម្រង់សំខាន់ៗនៃការគាំទ្រផ្នែកបង្ការ ដូចជាសេវាគាំពារសង្គម ឬ ការគាំទ្រដើម្បីដោះស្រាយបញ្ហាកង្វះ លទ្ធភាពទទួលបានសេវាសុខភាព និងអប់រំដោយឥតគិតថ្លៃឡើយ។

## គំហើញ៖ ភាពពាក់ព័ន្ធ

គំហើញពីការវាយតម្លៃបង្ហាញឱ្យឃើញនូវមតិឯកភាពគ្នាយ៉ាងខ្លាំង ក្នុងចំណោមភាគីពាក់ព័ន្ធសំខាន់ៗ អំពីភាពពាក់ព័ន្ធនៃគោលបំណង និងការរចនារបស់កម្មវិធីកិច្ចការពារកុមារ ដែលឆ្លុះបញ្ចាំងឱ្យឃើញនូវអាទិភាពរបស់ដៃគូអភិវឌ្ឍ និងអនុលោមទៅតាមអភិក្រមជាយុទ្ធសាស្ត្ររបស់អង្គការយូនីសេហ្វនាពេលបច្ចុប្បន្ន។ ការប្រកាន់យកអភិក្រមពង្រឹងប្រព័ន្ធក្នុងកិច្ចការពារកុមារដោយផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍសមត្ថភាពប្រព័ន្ធកិច្ចការពារកុមារថ្នាក់ជាតិ មានភាពស្របគ្នាយ៉ាងខ្លាំងជាមួយផែនការយុទ្ធសាស្ត្ររបស់អង្គការយូនីសេហ្វ ហើយត្រូវបានភាគីពាក់ព័ន្ធនានាទទួលស្គាល់ថាមានសារៈសំខាន់ជាពិសេសនៅក្នុងបរិបទ និងប្រវត្តិសាស្ត្រប្រទេសកម្ពុជា ដែលមានអ្នកចូលរួមពាក់ព័ន្ធច្រើនក្នុងកិច្ចការពារកុមារ ប៉ុន្តែ នៅខ្វះខាតការសម្របសម្រួលរវាងអ្នកពាក់ព័ន្ធទាំងនោះ។

បន្ថែមពីនេះទៀត ការសម្រេចចិត្តឱ្យកម្មវិធីនៅប្រទេសកម្ពុជាផ្តោតការយកចិត្តទុកដាក់ជាសំខាន់ទៅលើសមាហរណកម្មកុមារពីមណ្ឌលថែទាំ និងឱ្យកុមារចូលទៅទទួលការថែទាំតាមគ្រួសារ និងការថែទាំតាមសហគមន៍ ត្រូវបានរកឃើញថាមានភាពពាក់ព័ន្ធជាពិសេស បើគិតទៅលើតួលេខដ៏ខ្ពស់នៃកុមាររស់នៅក្នុងមណ្ឌលថែទាំកុមារ (ដែលគ្មានសុវត្ថិភាព និងមិនស្ថិតក្រោមច្បាប់ត្រួតពិនិត្យត្រឹមត្រូវ) នៅក្នុងប្រទេសកម្ពុជា និងការពឹងផ្អែកលើមណ្ឌលថែទាំកុមារក្នុងការឆ្លើយតបទៅនឹងសេចក្តីត្រូវការកិច្ចការពារកុមារ។ រដ្ឋាភិបាលកម្ពុជា ក៏បានគាំទ្រចំពោះវិធីសាស្ត្រនេះផងដែរ ដូចដែលបានបង្ហាញឱ្យឃើញតាមរយៈការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល ក្នុងគោលគំនិតទូទៅដើម្បីដកកុមារពីមណ្ឌលថែទាំកុមារ និងបានកំណត់គោលដៅបញ្ជូនកុមារចំនួន ៣០% ដែលកំពុងរស់នៅក្នុងមណ្ឌលថែទាំ (នៅពេលកំណត់ទីតាំងមណ្ឌល) ឱ្យវិលត្រឡប់ទៅរស់នៅជាមួយគ្រួសារ និងសហគមន៍របស់ពួកគេវិញប្រកបដោយសុវត្ថិភាព ត្រឹមឆ្នាំ ២០១៨។ គំហើញពីការវាយតម្លៃ ក៏បានឱ្យដឹងផងដែរថារដ្ឋាភិបាលមូលដ្ឋាន និងសហគមន៍កម្ពុជាមានការទទួលស្គាល់កាន់តែច្រើនឡើង នូវភាពចាំបាច់ក្នុងការធ្វើសមាហរណកម្មកុមារឱ្យទៅរស់នៅជាមួយគ្រួសារ និងសហគមន៍របស់ពួកគេវិញ។

## គំហើញ៖ ប្រសិទ្ធផល

ក្នុងរយៈពេលនៃការវាយតម្លៃនេះ អង្គការយូនីសេហ្វបានផ្តល់មូលនិធិគាំទ្រដល់សកម្មភាពជាច្រើនផ្សេងៗគ្នាយ៉ាងទូលំទូលាយ។ ការសម្រេចចិត្តជារួមអំពីគោលដៅផ្តល់មូលនិធិ និង ការវិនិយោគថវិកា ត្រូវបានរកឃើញថាមានលក្ខណៈជាយុទ្ធសាស្ត្រ និងមានប្រសិទ្ធភាពខ្ពស់។ អ្វីដែលគួរឱ្យកត់សម្គាល់ជាពិសេសនោះ គឺរបៀបគៀងគរភាពជាដៃគូប្រកបដោយប្រសិទ្ធភាពខ្ពស់ ដើម្បីគាំទ្រដល់ការផ្តោតយកចិត្តទុកដាក់សំខាន់របស់កម្មវិធី៖ ការបង្រួបបង្រួមកុមារទៅក្នុងការថែទាំតាមគ្រួសារប្រកបដោយសុវត្ថិភាព និង ការបង្ការការបំបែកកុមារពីគ្រួសារបន្ថែមទៀត។ ការទុកដាក់បុគ្គលិកសង្គមកិច្ចចំនួន៣១រូប ឱ្យបម្រើការងារពេញម៉ោង ក្រោមថវិកាគាំទ្រទាំងស្រុងពីមូលនិធិសហប្រជាជាតិ

ដើម្បីកុមារ នៅតាមមន្ទីរ ស.អ.យ និង អង្គការមិនមែនរដ្ឋាភិបាល បានជួយពង្រឹងទំនុកចិត្ត និង សមត្ថភាពបច្ចេកទេសផ្នែកការងារសង្គមកិច្ច។ សកម្មភាពនេះក៏បានលើកកម្ពស់ប្រសិទ្ធផលផងដែរ ដោយវាអនុញ្ញាតឱ្យបុគ្គលិកសង្គមកិច្ចដែលមានបទពិសោធន៍ខ្ពស់ មានពេលវេលាធ្វើការងារលើបញ្ហាដែលត្រូវការឱ្យពួកគេដោះស្រាយខ្លាំងបំផុត។ កិច្ចខិតខំរបស់មូលនិធិសហប្រជាជាតិដើម្បីកុមារ ក្នុងការគៀងគរសមត្ថភាព "នៅមូលដ្ឋាន" តាមរយៈការប្រើប្រាស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ/សង្កាត់ (គ.ក.ន.ក) ត្រូវបានរកឃើញថាមានប្រសិទ្ធភាពខ្ពស់បំផុត៖ ជនបង្គោល គ.ក.ន.ក មានទំនាក់ទំនងជិតស្និទ្ធជាមួយសហគមន៍ និង មានអាណត្តិការងារដើម្បីគាំទ្រដល់កុមារងាយរងគ្រោះ និងគ្រួសារ ដែលជាហេតុនាំឱ្យពួកគេស្ថិតនៅក្នុងតួនាទីមួយដ៏សមស្របបំផុត ក្នុងការផ្តល់ជំនួយសម្រាប់ការបន្តត្រួតពិនិត្យតាមដានករណីសមាហរណកម្ម និង សម្រាប់ក្រុមកុមារ "ដែលមានការប្រឈម" ដទៃទៀត។

ទិដ្ឋភាព និងចំណុចខ្លាំងមួយដ៏គួរឱ្យកត់សម្គាល់នៃកម្មវិធីកិច្ចការពារកុមាររបស់អង្គការយូនីសេហ្វ រួមមានវិសាលភាព ការធ្វើការងារជាលក្ខណៈអន្តរវិស័យ និងអភិក្រមកិច្ចការពារកុមារគ្រប់ជ្រុងជ្រោយ ដែលមានការចូលរួមពីក្រុមការងារផ្សេងៗគ្នារបស់អង្គការយូនីសេហ្វ។ បើទោះបីជាការធ្វើសមាហរណកម្មកុមារពីមណ្ឌលថែទាំ បាននិងកំពុងត្រូវបានចាត់ទុកថាជាអាទិភាពក៏ដោយ ប៉ុន្តែ ស្របពេលជាមួយគ្នានោះ អភិក្រមពង្រឹងប្រព័ន្ធមួយក៏ត្រូវបានធ្វើឡើងសម្រាប់កិច្ចការពារកុមារផងដែរ ដោយបង្កលក្ខណៈឱ្យមានការចូលរួមពីវិស័យអប់រំ សុខាភិបាល អភិបាលកិច្ចសង្គម ទំនាក់ទំនង កម្មវិធីអភិវឌ្ឍកុមារតូច (IECD) កម្មវិធីក្មេងជំទង់ និង ក្រុមការងារបរិយាប័ន្ន។ ការធ្វើបែបនេះបានបង្កលក្ខណៈឱ្យគេអាចដោះស្រាយបញ្ហាកិច្ចការពារកុមារជាមួយរដ្ឋាភិបាលនៅគ្រប់កម្រិត ស្ថាប័នចម្បងៗ អ្នកប្រកបអាជីពវិជ្ជាជីវៈ អ្នកអនុវត្តការងារជាមួយកុមារ ព្រមទាំងសាធារណជនផងដែរ។

## គំហើញ៖ និរន្តរភាព

អភិក្រមរបស់អង្គការយូនីសេហ្វក្នុងការកសាងសមត្ថភាពនៅថ្នាក់ជាតិ អ្នកផ្តល់សេវា និងអ្នកប្រកបវិជ្ជាជីវៈព្រមទាំងនៅក្នុងសហគមន៍មានលក្ខណៈអំណោយផលចំពោះការសម្រេចបានលទ្ធផលប្រកបដោយនិរន្តរភាព ហើយការវាយតម្លៃបានកំណត់ឃើញវិស័យនានា ដែលកម្មវិធីនេះបានរួមចំណែកប្រកបដោយអត្ថន័យចំពោះសមត្ថភាពនៅក្នុងប្រព័ន្ធកិច្ចការពារកុមារ ពោលគឺ តាមរយៈការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពផ្នែកសង្គមកិច្ចនៅមន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា និងរួមចំណែកដល់ការបង្កើតឱ្យមានការគ្រប់គ្រងករណីមូលដ្ឋាន។ ប៉ុន្តែ ការចូលរួមចំណែករបស់កម្មវិធីនេះ ស្ថិតនៅដំណាក់កាលដំបូងប៉ុណ្ណោះ ហើយនៅមានការងារសំខាន់ជាច្រើនទៀតដែលពុំទាន់បានធ្វើ ដើម្បីធានាថាអន្តរាគមន៍នឹងនាំទៅដល់ការសម្រេចបាននូវប្រព័ន្ធកិច្ចការពារកុមារគ្រប់ជ្រុងជ្រោយមួយ ដែលជាកម្មសិទ្ធិរបស់រដ្ឋាភិបាល និងអនុវត្តដោយរដ្ឋាភិបាល។

គំហើញពីការវាយតម្លៃបានឱ្យដឹងថា ការពឹងផ្អែកហួសប្រមាណលើអង្គការមិនមែនរដ្ឋាភិបាលក្នុងការផ្តល់សេវាកិច្ចការពារកុមារ អាចរារាំងដល់និរន្តរភាពរបស់កម្មវិធីនេះនៅក្នុងរយៈពេលវែង។ ថ្វីបើ ជាក់ស្តែងរដ្ឋាភិបាលនៅមិនទាន់អាចផ្តល់សេវាសង្គមកិច្ចដែលចាំបាច់នៅក្នុងករណីកិច្ចការពារកុមារសម្រាប់រយៈពេលចំពោះមុខនេះក្តី ប៉ុន្តែ **វាមានសារៈសំខាន់ក្នុងការបង្កើតប្រព័ន្ធគ្រប់គ្រងករណីការងារសង្គមកិច្ចមួយរបស់រាជរដ្ឋាភិបាល ដែលទទួលខុសត្រូវ**

**សម្រាប់មុខងារមូលដ្ឋានមួយចំនួន ទាក់ទងនឹងកិច្ចការពារកុមារ ដោយបញ្ជូនករណីទៅអង្គការមិនមែនរដ្ឋាភិបាល សម្រាប់សេវាឯកទេសទៅតាមភាពចាំបាច់។** ក្នុងលក្ខណៈជាវិធានការបណ្តោះអាសន្ន មន្ទីរ/ការិយាល័យ ស.អ.យ គប្បីធ្វើការងារឱ្យបានជិតស្និទ្ធជាមួយបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ដោយអនុញ្ញាតឱ្យអង្គការមិនមែនរដ្ឋាភិបាល ទទួលយកភារកិច្ចការងារសង្គមកិច្ចមួយចំនួន ដែលពួកគេមានសមត្ថភាពក្នុងការអនុវត្ត។

ជាចុងក្រោយ គំហើញពីការវាយតម្លៃបង្ហាញឱ្យឃើញថា និរន្តរភាពនៃការផ្តួចផ្តើមគំនិតក្នុងការធ្វើសមាហរណកម្ម/ការដកកុមារពីមណ្ឌលថែទាំកុមាររបស់អង្គការយូនីសេហ្វ ត្រូវបានធ្វើឱ្យចុះខ្សោយដោយសារកង្វះសេវាគាំទ្រគ្រួសារ និងសេវាថែទាំជំនួសនៅតាមសហគមន៍។ ករណីដែលកុមារជាជនរងគ្រោះនៃអំពើហិង្សា ការរំលោភបំពាន ឬការមិនអើពើ កម្រទទួលបានការឆ្លើយតបផ្នែកកិច្ចការពារកុមារណាស់ រហូតទាល់តែកុមារឈានដល់ចំណុចមានវិបត្តិ ហើយក្នុងករណីអវត្តមានជម្រើសជំនួសដទៃទៀត ធ្វើឱ្យទីបំផុតកុមារត្រូវធ្លាក់ទៅនៅក្នុងមណ្ឌលថែទាំកុមារ (ពេលខ្លះកុមារនៅជាបណ្តោះអាសន្ន ប៉ុន្តែជារឿយៗ កុមារមិននៅជាបណ្តោះអាសន្នទេ)។ បច្ចុប្បន្នការធ្វើសមាហរណកម្មកុមារពីមណ្ឌលថែទាំទៅទទួលការថែទាំតាមគ្រួសារ បានស្រូបយកកម្លាំងការងារផ្នែកសង្គមកិច្ចជាច្រើនរបស់រដ្ឋាភិបាល ហើយបន្សល់ទុកកម្លាំងតិចតួចប៉ុណ្ណោះសម្រាប់ធ្វើការងារឆ្លើយតបចំពោះកិច្ចពារកុមារប្រកបដោយអត្ថន័យ។

## សន្និដ្ឋាន

គោលដៅប្រកបដោយមហិច្ឆតាដែលកម្មវិធីបានកំណត់ មានការចាប់ផ្តើមបានល្អ ប៉ុន្តែ នៅមានការងារជាច្រើនទៀតដែលត្រូវធ្វើ ហើយនៅតែមានហានិភ័យ ដោយក្នុងនោះការអនុវត្តផែនការសកម្មភាពនានា ការធ្វើសមាហរណកម្មកុមារ ៣០% ដោយសុវត្ថិភាពពីមណ្ឌលថែទាំកុមារ និងការពង្រឹងប្រព័ន្ធកិច្ចការពារកុមារជាទូទៅ ទំនងជានឹងត្រូវរងការបន្ថយបង្អាក់ដោយឧបសគ្គផ្នែកនយោបាយ សេដ្ឋកិច្ច និងសង្គមវប្បធម៌ជាបន្តបន្ទាប់។

ក្របខ័ណ្ឌច្បាប់នៅតែមិនទាន់ពេញលក្ខណៈ បើទោះបីជាមានការចេញនូវអនុក្រឹត្យលេខ ៣៤ក៏ដោយ។ បច្ចុប្បន្ន ពុំទាន់មានច្បាប់ស្តីពីកិច្ចការពារកុមារគ្រប់ជ្រុងជ្រោយ ឬ មិនទាន់មានសូម្បីច្បាប់បន្ទាប់បន្សំ ដែលកំណត់ចែងលម្អិតអំពីអង្គភាពទទួលខុសត្រូវ និងមានគណនេយ្យភាពចំពោះការផ្តល់សេវាកិច្ចការពារកុមារ និងម្យ៉ាងវិញទៀត ច្បាប់ស្តីពីយុត្តិធម៌អនីតិជនដែលទើបអនុម័តនាពេលថ្មីៗនេះក៏មិនទាន់ត្រូវបានអនុវត្តឱ្យបានពេញលេញផងដែរ។

**ក្របខ័ណ្ឌស្ថាប័នប្រកបដោយប្រសិទ្ធភាពសម្រាប់កិច្ចការពារកុមារ ក៏នៅខ្វះខាតផងដែរ។ ពុំមានការកំណត់បែងចែក ថាតើស្ថាប័នណាមានការទទួលខុសត្រូវសម្រាប់ទិដ្ឋភាពណាខ្លះនៃបញ្ហាកិច្ចការពារកុមារ ដែលនាំឱ្យមានការអនុវត្តភារកិច្ចត្រួតគ្នាក្នុងករណីមួយចំនួន និង ក្នុងករណីដទៃទៀត នាំឱ្យការផ្តល់សេវាមិនបានគ្រប់គ្រាន់។ បន្ថែមពីនេះទៀត ពុំមានពិធីសារសម្រាប់ការបញ្ជូន ដែលនាំឱ្យអ្នកដែលបានកំណត់រកឃើញកុមារដែលត្រូវការកិច្ចការពារ ពុំមានសេចក្តីណែនាំ អំពីរបៀបឆ្លើយតបទៅនឹងករណីនោះ។ លើពីនេះទៀត ក៏ពុំមានភាពច្បាស់លាស់គ្រប់គ្រាន់ ថាតើកម្រិតណាមួយ (ថ្នាក់ខេត្ត ថ្នាក់ស្រុក ឬ ថ្នាក់ឃុំ) ដែលគួរផ្តល់អន្តរាគមន៍ដើម្បីការពារកុមារ។**

នាពេលបច្ចុប្បន្ន គេមិនទាន់អាចនិយាយបានថា មានបរិយាកាសសហគមន៍មួយដែលផ្តល់កិច្ចគាំទ្រនៅឡើយទេ បើទោះបីជាមានកិច្ចខិតខំអស់លទ្ធភាពពី គកនក ក៏ដោយ។ កង្វះថវិកាសម្រាប់កិច្ចការពារកុមារនៅថ្នាក់ឃុំ រួមផ្សំជាមួយនឹងកង្វះបុគ្គលិកដែលបានទទួលការបណ្តុះបណ្តាល និងបុគ្គលិកមានជំនាញ ធ្វើឱ្យកាន់តែមានការលំបាកក្នុងការផ្តល់នូវបរិយាកាសបែបនេះ។

កង្វះការវិនិយោគផ្នែកសេដ្ឋកិច្ចពីរាជរដ្ឋាភិបាលលើកិច្ចការពារកុមារ បានបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានទៅលើការអភិវឌ្ឍសេវារបស់រាជរដ្ឋាភិបាលប្រកបដោយគុណភាព និង ជាពិសេសគឺសេវាថែទាំជំនួស ដោយពឹងផ្អែកស្ទើរតែទាំងស្រុងទៅលើអង្គការមិនមែនរដ្ឋាភិបាល ដើម្បីផ្តល់សេវាបែបនេះ។ **ប្រសិនបើគ្មានការវិនិយោគធនធានបន្ថែម ទៅលើសេវាថែទាំតាមសហគមន៍ (និងជាពិសេសគឺការថែទាំដោយឪពុកម្តាយធម៌) ទូទាំងប្រទេសទេនោះ បញ្ហានៃការយកកុមារទៅដាក់ក្នុងមណ្ឌលដែលកំពុងបន្តកើតមាននេះ មិនទំនងថានឹងត្រូវបានដោះស្រាយប្រកប ដោយប្រសិទ្ធភាពឡើយ អាស្រ័យដោយបច្ចុប្បន្ន មណ្ឌលថែទាំកុមារនៅតែបន្តជាទម្រង់នៃការថែទាំជំនួសចម្បងមួយដែលមាន។**

ជារួម នៅខ្វះបុគ្គលិកសង្គមកិច្ចដែលបានទទួលការបណ្តុះបណ្តាល មានជំនាញ និងមានបទពិសោធន៍ នៅក្នុងសេវារបស់រដ្ឋាភិបាល សម្រាប់គ្រប់គ្រងបញ្ហាកិច្ចការពារកុមារស្មុគស្មាញដែលកើតមាន និង ពុំមានថវិកាគ្រប់គ្រាន់សម្រាប់ផ្តល់ជូនទៅតាមសេចក្តីត្រូវការរបស់កុមារ និងគ្រួសាររបស់ពួកគេ។

ការធ្វើសមាហរណកម្មកុមារជាមួយគ្រួសាររបស់ពួកគេ ឬ ទៅក្នុងការថែទាំជំនួសតាមសហគមន៍ ទទួលបានការស្វាគមន៍ ប៉ុន្តែ មានមេរៀនសំខាន់ៗមួយចំនួនដែលត្រូវរៀនសូត្រពីបទពិសោធន៍របស់កុមារ ដែលបានឆ្លងកាត់ការធ្វើសមាហរណកម្ម ទាក់ទងនឹងដំណើរការសមាហរណកម្ម។

## អនុសាសន៍

អនុសាសន៍ពីការវាយតម្លៃកម្មវិធីកិច្ចការពារកុមាររបស់អង្គការយូនីសេហ្វ ត្រូវបានធ្វើសពុលភាព និង ចាត់អាទិភាពដោយអ្នកពាក់ពន្ធ័ក្នុងដំណើរការវាយតម្លៃ ហើយនឹងត្រូវរៀបចំតាមលំដាប់លំដោយនៃអាទិភាពដូចខាងក្រោម។ សម្រាប់អនុសាសន៍ពេញលេញ និង តារាងពេលវេលា សូមមើលបន្ថែមក្នុងរបាយការណ៍ក្នុងទំព័រលេខ ៦៩។

### ១. ក្របខ័ណ្ឌការងារផ្នែកច្បាប់

ការវាយតម្លៃសូមផ្តល់អនុសាសន៍ឱ្យអង្គការយូនីសេហ្វបន្តផ្តល់អាទិភាពចំពោះកំណែទម្រង់ផ្នែកច្បាប់ និងផ្នែកស្ថាប័ន។ អង្គការយូនីសេហ្វគួរបន្តធ្វើការជាមួយរដ្ឋាភិបាល ដើម្បីពិនិត្យឡើងវិញលើអនុក្រឹត្យលេខ ៣៤ (និងបន្តធ្វើការបន្ថែមទៀតលើអនុក្រឹត្យលេខ ៥៤) និងដើម្បី**បង្កើតពិធីសារធ្វើការងារលម្អិត ឬនីតិវិធីប្រតិបត្តិបទដ្ឋានសម្រាប់ការផ្តល់សេវាកិច្ចការពារកុមារ។** លិខិតូបករណ៍ថ្មីនេះ ត្រូវកំណត់កាតព្វកិច្ចផ្នែកច្បាប់ចំពោះគ្រប់ស្ថាប័ន និងអ្នកប្រកបវិជ្ជាជីវៈអាជីពទាំងអស់ដែលធ្វើការងារជាមួយកុមារ ក្នុងការបញ្ជូនករណីសង្ស័យការរំលោភបំពានលើកុមារ ការមិនអើពើការគេងប្រវ័ញ្ចន៍ និងអំពើហិង្សាទាំងអស់ ត្រូវថែងអំពីស្ថាប័ន (យើងខ្ញុំសូមផ្តល់អនុសាសន៍ថាគួរតែជាការិយាល័យ ស.

**អ.យ ឬ មន្ទីរ ស.អ.យ នៅពេលដែលមានបុគ្គលិកសង្គមកិច្ចគ្រប់គ្រាន់នៅក្នុងមុខតំណែងនៅថ្នាក់ស្រុក) ទទួលការបញ្ជូន ស្ថាប័នទទួលខុសក្នុងការស៊ើបអង្កេត និងវាយតម្លៃហានិភ័យជាសក្ដានុពលចំពោះកុមារ ស្ថាប័នទទួលខុសត្រូវក្នុងការកំណត់ថាតើសេវាដែលមានដើម្បីផ្ដល់ជូនកុមារ និងគ្រួសារ និងស្ថាប័នណាដែលត្រូវទទួលខុសត្រូវក្នុងការដាក់ពាក្យទៅតុលាការដើម្បីផ្ទេរអំណាចមេបាដូចមានចែងនៅក្នុងច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ។**

## ២. ក្របខ័ណ្ឌការងារផ្នែកស្ថាប័ន៖ កិច្ចការពារកុមារ

ការវាយតម្លៃសូមផ្ដល់អនុសាសន៍ថា៖

- គ.ក.ន.ក គួរតែជាសេវាជួរមុខសម្រាប់កិច្ចការពារកុមារ ទទួលយកករណីក្នុងមូលដ្ឋានស្ដីពីការចោទប្រកាន់ថាកុមាររងការរំលោភបំពាន ប្រឈមហានិភ័យនៃការរំលោភបំពាន ឬកំពុងត្រូវការកិច្ចគាំទ្រដើម្បីបង្ការការបំបែកកុមារពីគ្រួសារ។
- គ.ក.ន.ក គួរគាំទ្រដល់កុមារ និងគ្រួសារដែលកំពុងត្រូវការជំនួយផ្នែកសម្ភារៈ និងការគាំទ្រដល់គ្រួសារក្នុងទម្រង់ដទៃទៀត ក្នុងករណីមិនចាំបាច់ត្រូវឱ្យមានអន្តរាគមន៍ផ្នែកកិច្ចការពារកុមារ។
- ក្នុងគ្រប់ករណីទាំងអស់ដែលមានមូលហេតុសមហេតុផលដើម្បីជឿថាកុមារបានទទួលរង ឬប្រឈមទៅនឹងការរំលោភបំពាន ការមិនអើពើ ឬការកេងប្រវ័ញ្ច ឬកុមារជាកម្មវត្ថុនៃអំពើហិង្សា ឬ មានការប្រឈមជាក់ស្ដែងទៅនឹងការបំបែកពីគ្រួសារ គួរធ្វើការបញ្ជូនករណីទៅមន្ទីរ ស.អ.យ (ឬការិយាល័យស.អ.យ ប្រសិនបើចំនួន និងសមត្ថភាពរបស់បុគ្គលិកសង្គមកិច្ចអាចកើនឡើង និងមានភាពប្រសើរឡើង) ដែលជាអ្នកទទួលខុសត្រូវក្នុងការស៊ើបអង្កេតករណីកិច្ចការពារកុមារ វាយតម្លៃ វិភាគហានិភ័យ និងធ្វើការសម្រេចចិត្តអំពីសេវាដែលគួរផ្ដល់ឱ្យ ពិនិត្យឡើងវិញលើករណី។ល។

## ៣. ក្របខ័ណ្ឌការងារផ្នែកស្ថាប័ន៖ នគរបាលជាតិ

ការវាយតម្លៃសូមផ្ដល់អនុសាសន៍ថា៖

(ក) អង្គភាពនគរបាលប្រឆាំងការជួញដូរ ទទួលយកសំណុំរឿងទូលំទូលាយ និងបំពេញមុខងារជាអង្គភាពនគរបាលឯកទេសសម្រាប់ករណីកិច្ចការពារកុមារ។

- រាល់ការរាយការណ៍អំពីបទល្មើសពាក់ព័ន្ធនឹងការរំលោភបំពានផ្លូវកាយ ឬ ផ្លូវភេទកុមារ ជូនទៅប៉ុស្តិ៍នគរបាលរដ្ឋបាលមូលដ្ឋាន គួរបញ្ជូនជាបន្ទាន់ទៅអង្គភាពនគរបាលប្រឆាំងការជួញដូរមនុស្ស ដើម្បីធ្វើការស៊ើបអង្កេត។ ចំពោះការបញ្ជូននេះ នគរបាលប្រឆាំងការជួញដូរ ក៏គប្បីបញ្ជូនករណីទៅឱ្យការិយាល័យ /មន្ទីរ ស.អ.យ ផងដែរ។
- ក្នុងករណីនគរបាលឃុំទទួលបានការរាយការណ៍អំពីអំពើហិង្សាក្នុងគ្រួសារ ដែលពាក់ព័ន្ធនឹងការធ្វើបាបផ្នែករាងកាយ និងផ្លូវភេទលើស្ត្រី ហើយមានកុមាររស់នៅក្នុងផ្ទះនោះដែរ មន្ត្រីនគរបាលដែលមានវត្តមាននៅក្នុង

ឧប្បត្តិហេតុនោះ គួរបញ្ជូនករណីកិច្ចការពារកុមារទៅឱ្យ គ.ក.ន.ក ហើយមន្ត្រី គ.ក.ន.ក ត្រូវបញ្ជូនករណីនោះបន្តទៅការិយាល័យ/មន្ទីរ ស.អ.យ ក្នុងករណីត្រូវការអន្តរាគមន៍កិច្ចការពារកុមារ។

(ខ) គួរបង្កើតឱ្យមាននីតិវិធីសារសម្រាប់ការធ្វើការងាររួមគ្នាមួយ រវាងអង្គភាពនគរបាលប្រឆាំងការជួញដូរមនុស្ស ជាមួយការិយាល័យ/មន្ទីរ ស.អ.យ /គ.ក.ន.ក ដោយមានចែងអំពីភារកិច្ច មុខងារ និងតួនាទីរបស់ស្ថាប័ននីមួយៗ និងរបៀបដែលពួកគេនឹងត្រូវធ្វើការជាមួយគ្នា។

(គ) ត្រូវផ្តល់ការបណ្តុះបណ្តាលបន្ថែមស្តីពីកិច្ចការពារកុមារជូនដល់មន្ត្រីនគរបាលនៅក្នុងអង្គភាពនគរបាលប្រឆាំងការជួញដូរមនុស្ស។

## ៤. កម្មវិធីអនុវត្តដាក់ពិន័យបែបវិជ្ជមាន

លទ្ធផលរបស់កម្មវិធីអនុវត្តដាក់ពិន័យបែបវិជ្ជមាន មានលក្ខណៈគួរជាទីពេញចិត្ត ហើយការវាយតម្លៃសូមផ្តល់អនុសាសន៍ថាកម្មវិធីនេះ គប្បីបន្តនៅក្នុងកម្មវិធីប្រចាំប្រទេសនាពេលបន្ទាប់ទៀត ហើយនឹងត្រូវពង្រីកទៅគ្រប់ដណ្តប់គ្រប់ខេត្តទាំងអស់ ប្រសិនបើអាចធ្វើទៅបាន។ ការវាយតម្លៃក៏សូមផ្តល់អនុសាសន៍ផងដែរថា កម្មវិធីចិញ្ចឹមកូនបែបវិជ្ជមានកម្រិតទី ១ គួរត្រូវបានផ្តល់ជូន និងបង្រៀនដល់ឪពុកម្តាយ។ល។ ស្របពេលជាមួយគ្នានឹងកម្មវិធីអនុវត្តដាក់ពិន័យបែបវិជ្ជមានដែរ។

## ៥. ការគ្រប់គ្រងករណីការងារសង្គមកិច្ច

ការវាយតម្លៃសូមផ្តល់អនុសាសន៍ថា៖

- **គួររៀបចំឱ្យមានប្រព័ន្ធគ្រប់គ្រងករណីការងារសង្គមកិច្ចជាបន្ទាន់ ហើយសំណុំឯកសារករណីគប្បីត្រូវបើក និងរក្សាទុកដោយស្ថាប័នទទួលខុសត្រូវក្នុងការស៊ើបអង្កេត វាយតម្លៃ វិភាគហានិភ័យ ធ្វើផែនការថែទាំ និងពិនិត្យករណីឡើងវិញ (ឧ. ការិយាល័យ/មន្ទីរ ស.អ.យ)។ ក្នុងករណីដែលកុមារកំពុងទទួលបានការផ្តល់សេវាពីអង្គការមិនមែនរដ្ឋាភិបាល បុគ្គលិកសង្គមកិច្ចម្នាក់របស់ការិយាល័យ /មន្ទីរ ស.អ.យ គួរតែបន្តជាស្ថាប័ននាំមុខដោយទទួលខុសត្រូវក្នុងការសម្របសម្រួលគ្រប់គ្រងករណី។**
- **អង្គការយូនីសេហ្វ គប្បីប្រឹងប្រែងឱ្យអស់លទ្ធភាពក្នុងការបន្តផ្តល់មូលនិធិគាំទ្រដល់បុគ្គលិកសង្គមកិច្ចដែលមានស្រាប់ និង បុគ្គលិកសង្គមកិច្ចថ្មីៗ ក្នុងរយៈពេលខ្លី និង បន្តស្វែងរកមតិគាំទ្រដើម្បីឱ្យពួកគេទទួលបានក្របខ័ណ្ឌការងាររដ្ឋាភិបាល។**

## ៦. សមាហរណកម្ម

ជំនួសឱ្យការកំណត់តួលេខគោលដៅសម្រាប់ការធ្វើសមាហរណកម្ម ការវាយតម្លៃសូមផ្តល់អនុសាសន៍ថា គួរតែមានការផ្លាស់ប្តូរគោលវិធីនៅក្នុងកម្មវិធីប្រចាំប្រទេសថ្មី ដោយត្រូវសង្កត់ធ្ងន់លើការកសាងសេវាផ្តល់ ការគាំទ្រដល់គ្រួសារ និងពង្រីក និងប្រើប្រាស់បរិយាកាសការថែទាំជំនួសតាមគ្រួសារ និង នៅតាមសហគមន៍ (ជាពិសេសគឺការ

ថែទាំដោយឪពុកម្តាយធម៌) ដោយការយកកុមារទៅដាក់ក្នុងមណ្ឌលថែទាំ គប្បីធ្វើឡើងតែក្នុងករណីលើកលែងមួយចំនួនប៉ុណ្ណោះ។ ការវាយតម្លៃសូមផ្តល់អនុសាសន៍ថា កុមារទាំងអស់ដែលកំពុងបន្តរស់នៅក្នុងមណ្ឌលថែទាំកុមារនៅចុងឆ្នាំ ២០១៨ គួរជាកម្មវត្ថុនៃ**ការវាយតម្លៃរហ័ស នៅដើមឆ្នាំ ២០១៩ ដើម្បីកំណត់ថាតើអាចមានលទ្ធភាពធ្វើសមាហរណកម្មពួកគេ ដែរឬទេ។**

ចាំបាច់ត្រូវពិនិត្យឡើងវិញលើដំណើរការធ្វើសមាហរណកម្ម ដោយហេតុថាមានការរកឃើញថាកុមារដែលត្រូវបានធ្វើសមាហរណកម្មជាច្រើនបានបាត់ខ្លួន ឬ បានក្លាយជាកម្មវត្ថុនៃការព្រួយបារម្ភ។ ការវាយតម្លៃសូមផ្តល់អនុសាសន៍ថា សេចក្តីព្រាង**គោលការណ៍ណែនាំសម្រាប់ការបង្រួបបង្រួម និងសមាហរណកម្មកុមារពីមណ្ឌលថែទាំកុមារក្នុងប្រទេសកម្ពុជា គួរត្រូវបានយកមកអនុវត្ត ហើយបុគ្គលិកសង្គមកិច្ចរបស់មន្ទីរ ស.អ.យ គួរបានទទួលការបណ្តុះបណ្តាលបន្ថែម ស្តីពីនីតិវិធីដែលមានចែងនៅក្នុងគោលការណ៍ណែនាំនេះ។ ការវាយតម្លៃក៏សូមផ្តល់អនុសាសន៍ផងដែរថា គួរដាក់ឱ្យមានប្រព័ន្ធពិនិត្យតាមដានម៉ត់ចត់ជាងនេះ ដោយមានការចុះពិនិត្យជាទៀងទាត់ដោយបុគ្គលិកសង្គមកិច្ច រួមជាមួយនឹងផែនការយថាភាពក្នុងករណីដែលការទុកដាក់កុមារទទួលរងបរាជ័យ/បែកបាក់។**

## ៧. ការបណ្តុះបណ្តាល

ថ្វីបើមានការបណ្តុះបណ្តាលផ្តល់ជូនដល់បុគ្គលិកសង្គមកិច្ច និងមន្ត្រីឃុំក្តី ប៉ុន្តែ ចាំបាច់ត្រូវមានការបណ្តុះបណ្តាលបន្ថែមទៀត។ ការវាយតម្លៃសូមផ្តល់អនុសាសន៍ថា៖

- គួរបន្តផ្តល់ការបណ្តុះបណ្តាលបែបអនុវត្តជាក់ស្តែង និងការបង្វឹកឱ្យអនុវត្តផ្ទាល់ជូនដល់បុគ្គលិកសង្គមកិច្ចរបស់មន្ទីរ ស.អ.យ និងការិយាល័យ ស.អ.យ ឱ្យបានទៀងទាត់ក្នុងអំឡុងពេលនៃកម្មវិធីប្រចាំប្រទេសខាងមុខ ដើម្បី "បង្កើតភាពជំនាញកម្រិតអាជីព" លើផ្នែកសេវាកិច្ចការពារកុមារ។
- ការបណ្តុះបណ្តាលដើម្បីឱ្យអាចស្គាល់ និងកំណត់អត្តសញ្ញាណការរំលោភបំពានលើកុមារ ផ្តល់ជូនដល់សមាជិក គ.ក.ន.ក។
- ការបណ្តុះបណ្តាលស្តីពីការវាយតម្លៃគ្រួសារ និងការវិភាគហានិភ័យ គួរផ្តល់ជូនដល់បុគ្គលិកសង្គមកិច្ចរបស់រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល។

ចាំបាច់ត្រូវមានការបណ្តុះបណ្តាលផងដែរ សម្រាប់អង្គការមិនមែនរដ្ឋាភិបាលស្តីពីការធ្វើការជាមួយកុមារអនាថា និងសម្រាប់អ្នកប្រកបវិជ្ជាជីវៈផ្នែកសុខាភិបាល និងអប់រំ ស្តីពីកាតព្វកិច្ចរបស់អ្នកប្រកបវិជ្ជាជីវៈក្នុងការរក្សាសុវត្ថិភាពកុមារ និង ដំណើរការបញ្ជូនករណី។

## ៨. ថវិកា

ការវាយតម្លៃសូមផ្តល់អនុសាសន៍ថាអង្គការយូនីសេហ្វ គប្បីប្រើឥទ្ធិពល និង អានុភាពរបស់ខ្លួន ជាមួយរដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីចាត់កញ្ចប់ថវិកាដោយឡែក/បង្កើនមូលនិធិសម្រាប់សេវាកិច្ចការពារកុមារ នៅក្នុងកម្មវិធីប្រចាំប្រទេសបន្ទាប់ ស្របតាមការទាញសេចក្តីសន្និដ្ឋានលើសង្កេតរបស់គណៈកម្មាធិការអង្គការ

សហប្រជាជាតិស្តីពីសិទ្ធិកុមារ ក្រោយពេលដែលប្រទេសកម្ពុជាបានផ្តល់របាយការណ៍តាមកាលកំណត់លើកទី២ និងលើកទី៣។[7]

## ៩. ការរៀបចំផែនការ

ការវាយតម្លៃសូមផ្តល់អនុសាសន៍ថាអង្គការយូនីសេហ្វគប្បីលើកទឹកចិត្តមន្ទីរ ស.អ.យ សហការជាមួយអង្គការមិនមែនរដ្ឋាភិបាល ក្នុងការរៀបចំសេចក្តីព្រាងផែនការសេវាកិច្ចការពារកុមារប្រចាំឆមាស។ ផែនការនេះគួរមានចែងអំពីសេចក្តីត្រូវការរបស់កុមារនៅក្នុងខេត្ត សេវាដែលមានស្រាប់ដែលមានសមត្ថភាពអាចឆ្លើយតបតាមសេចក្តីត្រូវការទាំងនោះ សេចក្តីត្រូវការដែលនៅពុំទាន់ត្រូវបានឆ្លើយតប និងថាតើមន្ទីរ ស.អ.យ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នដទៃទៀតមានផែនការដើម្បីបំពេញចន្លោះប្រហោង ផ្នែកសេវាកម្មដូចដែលបានគូសបញ្ជាក់នៅក្នុងរបាយការណ៍នេះដោយរបៀបណា។

[7] CRC/C/KHM/CO/2-3, 3 August 2011 para. 17.